# មាតិការ

ល.រ ទំព័រ

**១. និយមន័យបាតុភូតចិត្ត** ...... 3
**២. ធម្មជាតិនៃបាតុភូតចិត្ត** ...... **3**
ក. ចិត្តរបស់មនុស្សគឺជាចំណាំងរបស់តថភាពសត្យានុម័តរបស់ខួរក្បាល ......4
ខ. អ្វីទៅហៅថាចំណាំង? ......**5**
២.១ តថាភាពសត្យានុម័តៈ......5
២.២ ចរិតអត្តនោម័តរបស់ចិត្ត......5
២.៣ ចិត្តជាមុខងាររបស់ខួរក្បាល ......6
២.៤ ចិត្តជាបទពិសោធន៍......6
.បាតុភូតចិត្តរបស់មនុស្ស ......7
.បាតុភូតចិត្តជាលទ្ធផលនៃសង្គមប្រវត្តិ ......7
.ចិត្តជាសម្បត្តិផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ ......7
ក. ក្នុងលំនាំអភិវឌ្ឍន៍នៃសង្គមប្រវត្តិ......7
ខ. ចិត្តជាបទពិសោធន៍ដែលបង្កប់ អត្តន័យសង្គមប្រវត្តិ ......7
គ. ចិត្តរបស់បុគ្គល ......8
**៣. មុខងាររបស់ចិត្ត** ......8
**៤.ប្រភេទនៃបាតុភូតចិត្ត** ......9
ក. លំនាំចិត្តៈ ......9
លំនាំសញ្ចេតនា ......9
លំនាំឆន្ទៈ......9
ខ. សភាពចិត្តៈ ......9
គ. លក្ខណៈចិត្តៈ ......10
**៥. វិធីសិក្សាចិត្តវិទ្យា** ...... **10**
ក.វិធីសង្កេតៈ......10
ខ. វិធីវិភាគផលិតផលសកម្មភាពៈ ......10
ឧទាហរណ៍ៈ......10
គ. វិធីសន្ទនាៈ......10

ឃ.វិធីតេស្តៈ....................................................................................................11
ង.វិធីពិសោធន៍ៈ...............................................................................................11
ពិសោធន៍ធម្មតាៈ .........................................................................................11
ពិសោធន៍ក្នុងមន្ទីរពិសោធន៍ៈ ....................................................... 11

# ចិត្តវិទ្យាជាអ្វី?

ចិត្តវិទ្យា គឺជាវិទ្យាសាស្ត្រ ដែលសិក្សាពីបាតុភូតចិត្ត។ ចិត្តវិទ្យា ជាវិទ្យាសាស្ត្រព្រោះ ចិត្តវិទ្យាមានកម្មវត្ថុសិក្សាច្បាស់លាស់ មានវិធីសិក្សាជាក់លាក់ និងនាំមកនូវផលប្រយោជន៍ដល់សង្គមមនុស្ស។

**+កម្មវត្ថុសិក្សានៃចិត្តវិទ្យា**

កម្មវត្ថុសិក្សានៃចិត្តវិទ្យា គឺបាតុភូតចិត្តរបស់មនុស្ស។

**១/ និយមន័យបាតុភូតចិត្ត**

បាតុភូតចិត្ត គឺជាបាតុភូតទាំងឡាយ ដែលប្រព្រឹត្តនៅក្នុងខួរក្បាលរបស់មនុស្ស និងសម្តែង ចេញមកក្រៅតាមរយៈអំពើ និងអាកប្បកិរិយា( កាយវិការ ទឹកមុខ ពាក្យសម្តី...)។

ឧទាហរណ៍:បុគ្គល"ក"សប្បាយរីករាយមានទឹកមុខញញឹម

បុគ្គល"ខ" ជាមនុស្សកាច មានកាយវិការច្រងេងច្រងាង

បាតុភូតចិត្តមានលក្ខណៈខុសប្លែកពីបាតុភូតដទៃទៀតដូចជា:

- បាតុភូតរូប: ឧទាហរណ៍: ព្រះអាទិត្យបំភ្លឺផែនដី ទឹកដាំយូរហួតអស់
- បាតុភូតគីមី: ឧទាហរណ៍: បាយទុកយូរជុះផ្សិត
- បាតុភូតជីវសាស្ត្រ: ឧទាហរណ៍:ត្រីស្រង់ចេញពីទឹកងាប់
- បាតុភូតអគ្គីសនី: ឧទាហរណ៍: មានផ្គររន្ទះពេលមានភ្លៀង
- បាតុភូតមេកានិច: ឧទាហរណ៍: រទេះភ្លើងបរលើផ្លូវដែក

**២/ធម្មជាតិនៃបាតុភូតចិត្ត**

- **តាមទស្សនៈម៉ាក់** ធម្មជាតិនៃបាតុភូតចិត្តគឺ:

"ចិត្តជារូបភាពអត្តនោម័ត នៃតថភាពបរានុម័តក្នុងខួរក្បាលរបស់មនុស្សម្នាក់ៗ។ វាមានចរិតសង្គមប្រវត្តិ។"

បញ្ហាជាមូលដ្ឋានគ្រឹះដំបូងបង្អស់របស់ចិត្តវិទ្យាគឺថា តើធម្មជាតិនៃចិត្តគឺអ្វីទៅ? នៅក្នុងដំណាក់កាលអភិវឌ្ឍន៍នីមួយៗរបស់មនុស្ស គេបានផ្តល់នូវចម្លើយប្លែកៗពីគ្នាចំពោះសំនួរនេះ។ កាលពីសម័យដែលមនុស្សមិនទាន់ឈានទៅដល់ភាពជឿនលឿនទាន់សម័យ ហើយមិនទាន់មានសមត្ថភាពនៅចំពោះមុខធម្មជាតិនៅឡើយ បាតុភូតចិត្តត្រូវគេចាត់ទុកថាជាឥទ្ធិពល ឬជាកម្លាំងរបស់ព្រះអាទិទេព ។ លុះដល់ពេលសាសនាចាប់កកើតមាននៅលើផែនដីយើងនេះ បាតុភូតចិត្តត្រូវបានចាត់ទុកថា ជាដង្ហើមរបស់ព្រះអាទិទេពទៅវិញ។

សព្វថ្ងៃនេះវិទ្យាសាស្រ្តកំពុងតែអភិវឌ្ឍន៍ឡើងយ៉ាងខ្លាំងក្លា អាចអោយយើងយកមកប្រើជាមូលដ្ឋាន ដ៏រឹងមាំដើម្បីច្រានចោលលើរាល់អបិយជំនឿស្តីអំពីចិត្តរបស់មនុស្ស ។ ចិត្តវិទ្យាដែលប្រកបទៅដោយលក្ខណៈវិទ្យាសាស្រ្តដ៏ត្រឹមត្រូវបានផ្តល់នូវចម្លើយ ដ៏ច្បាស់លាស់ប្រាកដប្រជា ចំពោះសំនួរដែលមនុស្សចោទសួរ តាំងពីយូរលង់ណាស់មកហើយ គឺ ចិត្តរបស់មនុស្សគឺជាចំណាំងរបស់តថភាពសន្យានុម័តដោយខួរក្បាលរបស់មនុស្ស ហើយចំណាំងមានលក្ខណៈអត្តនោម័តនេះ គឺជាធម្មជាតិរបស់សង្គមប្រវត្តិ ។

**ក/ចិត្តរបស់មនុស្សគឺជាចំណាំងរបស់តថភាពសត្យានុម័តរបស់ខួរក្បាល**

ចិត្តរបស់មនុស្សកើតមកពីរូបភាពនៃតថភាពសត្យានុម័ត ដែលស្ថិតនៅក្រៅញាណរបស់មនុស្ស ហើយដែលត្រូវបានកត់ត្រាទុកក្នុងខួរក្បាលរបស់មនុស្ស។ នេះហើយដែលគេហៅថា បាតុភូតសតិអារម្មណ៍។

ដើម្បីយល់អោយកាន់តែច្បាស់ចំពោះអំណះអំណាងនេះ គេគប្បីយល់ថា

ខ/**អ្វីទៅហៅថាចំណាំង?**

ចំណាំងគឺជាលំនាំអន្តរកម្ម រវាងប្រព័ន្ធរូបធាតុពីរ ក្នុងពេលដំណាលគ្នា ហើយជាលទ្ធផលដែលកើតចេញពីលំនាំនោះ។

**២.១ តថាភាពសត្យានុម័តៈ**

តថភាពសត្យានុម័ត គឺជាអ្វីៗដែលស្ថិតនៅក្រៅញាណរបស់មនុស្ស ហើយជាប្រភពចិត្តរបស់មនុស្ស ។ តថភាពសត្យានុម័តនោះក៏គ្មានរូបភាពចិត្ត នៅក្នុងខួរក្បាលមនុស្សដែរ។ ដូច្នេះរូបភាពចិត្តកើតឡើង និងផ្សារភ្ជាប់យ៉ាង ជិតស្និទ្ធទៅនឹងតថភាពសត្យានុម័ត នៅក្នុងខួរក្បាលរបស់មនុស្ស បានន័យ ថា រូបភាពចិត្តផ្សារភ្ជាប់ទៅនឹងអ្វីៗ ដែលបុគ្គលម្នាក់ៗមានទំនាក់ទំនងជាមួយ និងមជ្ឈដ្ឋានជុំវិញខ្លួន ក្នុងជីវភាពរស់នៅ និងក្នុងការងារ។ចំពោះមនុស្សម្នាក់ៗ ប្រភពចិត្តកើតមានគ្រប់ពេលវេលា។

**តថភាពសត្យានុម័ត** ជាប្រភព និងជាខ្លឹមសារនៃចិត្តរបស់មនុស្ស។

តថភាពសត្យានុម័តត្រូវបានឆ្លុះបញ្ចាំងចូលក្នុងខួរក្បាលរបស់មនុស្ស ហើយបង្កើត បានជារូបភាពចិត្ត។

បើគ្មានតថភាពសត្យានុម័ត ក៏គ្មានរូបភាពចិត្តដែរ។

រូបភាពចិត្តផ្សារភ្ជាប់តថភាពសត្យានុម័តយ៉ាងជិតស្និទ្ធទៅនឹងខួរក្បាល។ ហើយដោយសារតែមនុស្សមានទំនាក់ទំនងជាមួយមជ្ឈដ្ឋានជុំវិញ ដូច្នេះរូបភាពចិត្តកកើតឡើងគ្រប់ពេលវេលា។

**២.២ ចរិតអត្តនោម័តរបស់ចិត្ត**

រូបភាពចិត្តដែលកើតពីវត្ថុមួយ ឬ បាតុភូតណាមួយ ដែលសន្និតនៅក្នុង ខួរក្បាលរបស់មនុស្សម្នាក់ៗតែងតែខុសប្លែកគ្នាពីមនុស្សម្នាក់ទៀត ពីព្រោះ ការឆ្លុះបញ្ចាំងរូបភាពចូលទៅក្នុងខួរក្បាលមនុស្សម្នាក់នេះ ត្រូវបានផ្លាស់ប្តូរ ទៅតាមការយល់ដឹង បទពិសោធន៍ និងវិសេសភាពរបស់បុគ្គលម្នាក់ៗ បាន ន័យថា វត្ថុ ឬ បាតុភូតដែលមនុស្សម្នាក់ៗបានពិនិត្យសង្កេតនិង វាយតំលៃ មានភាពខុសប្លែកគ្នា ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត។ ជួនកាលវង្វាយតម្លៃ នេះមានការខុសប្លែកគ្នា ទៅតាមចំណង់ចំណូលចិត្ត។ ដូច្នេះបានន័យថា បាតុភូតចិត្តមានរូបភាពអត្តនោម័ត ពីបុគ្គលម្នាក់ ទៅបុគ្គលម្នាក់ទៀត។

ឧទាហរណ៍ បងប្អូនពីរនាក់ ម្នាក់ចូលចិត្តរៀនភាសាបារាំង ម្នាក់ទៀត ចូលចិត្តរៀនភាសាអង់គ្លេស ។ បុរសពីរនាក់អោយតម្លៃទៅលើរថយន្តមួយ។

ម្នាក់ថា រថយន្តម៉ាកនេះខ្សោយ ម្នាក់ទៀតថារថយន្តម៉ាកដដែលនេះស្រួលប្រើ ណាស់ ព្រោះវាស៊ីសាំងតិច ។

សរុបសេចក្តីមកបានន័យថា វត្ថុតែមួយធ្វើអោយមនុស្សម្នាក់។មានរូបភាពចិត្តផ្សេងពីគ្នា។ តថភាពសត្យានុម័តជាប្រភពផង និងខ្លឹមសារសម្រាប់រូបភាពចិត្តរបស់បុគ្គលម្នាក់។

**២.៣ ចិត្តជាមុខងាររបស់ខួរក្បាល**

មូលដ្ឋានរូបធាតុនៃបាតុភូតចិត្ត គឺខួរក្បាល និងសំបកខួរក្បាល។ គ្មានខួរក្បាល គឺគ្មានចិត្ត ឬខួរក្បាលមិនធម្មតានាំឲ្យចិត្តមិនធម្មតា។ ឧទាហរណ៍: “មនុស្សវិកលចរិក”។

ប៉ុន្តែចិត្តមិនមែនជាខួរក្បាលទេ ព្រោះចិត្តមិនមែនជារូបធាតុ ដែលបញ្ចេញដោយ ខួរក្បាលដូចជាថ្លើមបញ្ចេញទឹកប្រមាត់នោះទេ។

ពេលណាខួរក្បាលទទួលរំញោច ខួរក្បាលបញ្ជាទៅសរីរាង្គណាមួយ ពេលនោះមនុស្សសម្តែងចេញនូវសកម្មភាព ដូចនេះគេថា ចិត្តជាមុខងាររបស់ខួរក្បាល។

**ឧទាហរណ៍:** គ្រូហៅសរសេរតាមអាន(រំញោច) សិស្សស្តាប់(បាតុភូតចិត្ត) រួចសរសេរតាមអំនានរបស់គ្រូ(សកម្មភាព)។

**២.៤ ចិត្តជាបទពិសោធន៍** ដែលមានចរិតសង្គមប្រវត្តិ ហើយដែលមនុស្សបានប្រែក្លាយជាសម្បត្តិផ្ទាល់ខ្លួន

✓ **បាតុភូតចិត្តរបស់មនុស្ស** គឺជាបាតុភូតពិសេសដែលមានតាំងពីមានមនុស្សនៅលើផែនដី។

✓ **បាតុភូតចិត្តជាលទ្ធផលនៃសង្គមប្រវត្តិ** គឺជាសកម្មភាពរបស់បុគ្គលបានប្រែក្លាយផលរួមទាំងនោះឲ្យទៅជា ”ចិត្តរបស់បុគ្គលម្នាក់” ព្រោះថាបុគ្គលរស់នៅ និងធ្វើសកម្មភាពក្នុងលក្ខខណ្ឌសង្គមប្រវត្តិជាក់លាក់។

✓ **ចិត្តជាសម្បត្តិផ្ទាល់ខ្លួនរបស់មនុស្សម្នាក់** ប៉ុន្តែសម្បត្តិនេះជាសម្បត្តិមនុស្សជាតិ របស់សម័យកាល របស់ទឹកដី របស់ប្រទេសជាតិ របស់ជនជាតិ របស់គ្រួសារ ហើយសម្បត្តិទាំងនេះបង្កប់នូវខ្លឹមសារប្រវត្តិសាស្ត្រជាប់ជានិច្ច។ សម្បត្តិផ្ទាល់ខ្លួនគឺជាសម្បត្តិរួមនៅក្នុងបុគ្គលម្នាក់ៗ

**ក/ ក្នុងលំនាំអភិវឌ្ឍន៍នៃសង្គមប្រវត្តិ** មនុស្សបានប្រមូលផ្ដុំបទពិសោធន៍ជាច្រើន ក្នុងនោះចំណេះដឹងពីសង្គម ធម្មជាតិ និងមនុស្ស។ បទពិសោធន៍ទាំងនោះត្រូវបានផ្ដិតជាប់ នឹងឧបករណ៍ពលកម្ម និងស្នាដៃស្ថាបត្យកម្ម ស្នាដៃវិទ្យាសាស្ត្រ អក្សរសិល៍ សិល្បៈ និងបទបញ្ញាសង្គម។ ពីជំនាន់មួយទៅជំនាន់មួយ គេប្រមូលចំណេះដឹងទាំងនោះ តាមរយៈល្បែងកំសាន្ត ពលកម្ម និងទំនាក់ទំនងសង្គម។ មនុស្សម្នាក់ៗយល់ និងជ្រួតជ្រាបនូវចំណេះដឹងទាំងនេះ ហើយប្រែក្លាយឲ្យទៅជាបទពិសោធន៍ សម្បទា សញ្ចេតនា របស់ខ្លួនផ្ទាល់។ ទាំងនោះគេហៅថា "ចិត្តរបស់បុគ្គល"។ ក្នុងពេលដែលគេយល់ជ្រួតជ្រាបពីចំណេះដឹងទាំងនោះ បុគ្គលម្នាក់ៗស្រាវជ្រាវចំណេះដឹងថ្មី និងកែប្រែផលិតកម្មទីតាមចំណេះដឹងថ្មីទាំងនោះ ហើយទន្ទឹមនឹងនោះបទពិសោធន៍របស់គេកាន់តែសម្បូរ។

**ខ/ចិត្តជាបទពិសោធន៍ដែលបង្កប់ អត្តន័យសង្គមប្រវត្តិ**

ចិត្តរបស់មនុស្សជាលទ្ធផលនៃសង្គម តាមរយៈសកម្មភាពរបស់ខ្លួនបុគ្គលម្នាក់ៗ បានប្រែក្លាយទៅជាផលរួមរបស់សង្គមប្រវត្តិឲ្យទៅជាចិត្តរបស់គេម្នាក់ៗ ព្រោះពីជំនាន់មួយទៅជំនាន់មួយទៀតបុគ្គលម្នាក់ៗនិងធ្វើសកម្មភាពនៅក្នុងលក្ខខណ្ឌសង្គមប្រវត្តិដ៏ប្រាកដមួយ ។

ចិត្តវិទ្យាជាសម្បត្តិផ្ទាល់របស់បុគ្គលម្នាក់ៗ សម្បត្តិក្នុងសង្គមគឺជាសម្បត្តិ របស់សង្គមជាតិ មនុស្សម្នាក់ៗរស់នៅក្នុងសម័យកាល សុទ្ធសឹងតែឆ្លងកាត់ព្រឹត្តិការណ៍ ឬ ហេតុការណ៍ផ្សេងៗ ឬ បទពិសោធន៍ដែលគេធ្លាប់ឆ្លងកាត់ ។

ដូច្នេះចិត្តរបស់មនុស្សបង្កប់ទៅដោយខ្លឹមសារសង្គមប្រវត្តិជាប់ជានិច្ច។

មនុស្សទទួលបទពិសោធន៍ក្នុងសង្គមដូចជាចំណេះដឹង ពីសង្គម និងពីវិទ្យាសាស្ត្របច្ចេកទេស។ បទពិសោធន៍ និង ចំណេះដឹងទាំងនោះ តែងតែផ្សារភ្ជាប់ទៅនឹង ស្នាដៃស្ថាបត្យកម្ម អក្សរសិល្ប៍ វប្បធម៌ សិល្បៈ និង ច្បាប់។

ចំណេះដឹង និងបទពិសោធន៍ក្នុងពលកម្ម ត្រូវបានផ្ទេរឲ្យមនុស្សពីជំនាន់មួយទៅជំនាន់មួយទៀត ។ មនុស្សតែងតែជ្រួតជ្រាបយល់ដឹងនូវសមិទ្ធផលទាំងនេះ ហើយបានប្រែក្លាយវាឲ្យទៅជាបទពិសោធន៍ផ្ទាល់ខ្លួន គួបផ្សំនិងចំណេះដឹងថ្មីៗថែមទៀត សម្តៅធ្វើឲ្យបទពិសោធន៍ និង ស្នាដៃរបស់គេកាន់តែសម្បូរបែបឡើង ។ ដរាបណាដែលមនុស្សមានទឹកចិត្តក្លាហានភ្ញាក់រលឹកចូលរួមយ៉ាងសកម្ម ក្នុងការងារសង្គម ក្នុងការសិក្សា ក្នុងការប្រតិបត្តិ ដរាបនោះចិត្តរបស់គេកាន់តែមានភាពសម្បូរបែប ហើយក្លាហានឡើង។

**គ/“ចិត្តរបស់បុគ្គល”** កាន់តែសម្បូរ កាលណាគេចូលរួមយ៉ាងសកម្មក្លៀវក្លាក្នុងការងារ ពលកម្ម ក្នុងការសិក្សា និងចូលរួមយ៉ាងក្លៀវក្លាបំផុតក្នុងសកម្មភាពសង្គម ដើម្បីជាការពង្រីកនូវបទពិសោធន៍ឲ្យកាន់តែទូលំទូលាយ។

**៣/ មុខងាររបស់ចិត្ត**

បាតុភូតចិត្តទាំងឡាយ ផ្សារភ្ជាប់ទៅនឹងអំពើ។ វាស្តែងចេញក្នុងអំពើ។

- **ចិត្តមានមុខងារបីគឺ:**

✓ ក/តម្រង់ទិសណែនាំ ដឹកនាំអំពើរបស់មនុស្ស។

ឧទាហរណ៍: អ្នកប្រមាញ់សំដៅទៅកន្លែងដែលសត្វយំ។

✓ ខ/រុញច្រានធ្វើឲ្យកាន់តែខ្លាំង នូវអំពើទាំងឡាយ។

ឧទាហរណ៍:ទឹកចិត្តឪពុកម្តាយស្រឡាញ់កូន ធ្វើឲ្យពួកគាត់ហ៊ានតស៊ូគ្រប់ឧបសគ្គ ធ្វើការងារដើម្បីរកលុយមកផ្គត់ផ្គង់គ្រួសារ និងការរៀនសូត្ររបស់កូន។

✓ គ/តម្រែតម្រង់ ឬកែតម្រូវអំពើ:នៅក្នុងសកម្មភាព គេអាចភ័ន្តច្រឡំ។ គោលបំណងដែលយើងបានកំណត់ជួយឲ្យមានភាពត្រឹមត្រូវពិតប្រាកដ និងមានប្រយោជន៍ជាងមុន។

## ៤.ប្រភេទនៃបាតុភូតចិត្ត

គេចែកបាតុភូតចិត្តជាបីប្រភេទ:

**ក/ លំនាំចិត្ត:**គឺជាបាតុភូតទាំងឡាយណា ដែលប្រព្រឹត្តក្នុងរយ:ពេលមួយខ្លី វាមានការចាប់ ផ្តើម ការប្រព្រឹត្តទៅ និងការបញ្ចប់។ លំនាំជាមូលដ្ឋានគឺ:

លំនាំពុទ្ធិដូចជាឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ លំនឹក ការគិត ភាសា រូបារម្មណ៍។ល។ ដែលបង្កើតបានជាជីវិតពុទ្ធិរបស់មនុស្ស។

- **លំនាំសញ្ចេតនា** ដូចជាចិត្តរំភើប និងសញ្ចេតនា ដែលបង្កើតបានជាជីវិតសញ្ចេតនារបស់មនុស្ស។
- **លំនាំឆន្ទ:** និងអំពើឆន្ទ:ដែលបង្កើតជាជីវិតឆន្ទ:របស់មនុស្ស។គឺនៅក្នុងទិដ្ឋភាពទាំងបីនេះហើយ ដែលស្តែងចេញនូវសកម្មភាពចិត្តរបស់មនុស្ស។

**ខ/ សភាពចិត្ត:**គឺជាបាតុភូតចិត្ត ដែលប្រព្រឹត្តទៅអស់រយ:ពេលយូរបន្តិច។ ជាធម្មតាសភាពចិត្តដើរតាមលំនាំចិត្តដទៃទៀត ដោយយកលំនាំចិត្តទាំងនោះធ្វើជាបង្អែក។

ឧទាហរណ៍: ប្រុងប្រយ័ត្នក្នុងការស្តាប់គ្រូពន្យល់។

**គ/ លក្ខណ:ចិត្ត:**គឺជាបាតុភូតចិត្តទាំងឡាយណា ដែលប្រព្រឹត្តទៅអស់រយ:ពេលយ៉ាងវែង ជូនកាលរហូតអស់មួយជីវិត ហើយដែលមានសភាពនឹងនរ ចំពោះបុគ្គលមួយជាក់លាក់។

## ៥. វិធីសិក្សាចិត្តវិទ្យា

**ក/វិធីសង្កេត:**ជាវិធីដែលគេប្រើច្រើនជាងគេក្នុងចិត្តវិទ្យា។ វិធីនេះសិក្សាអំពីសកម្មភាព (កាយវិការ ទឹកមុខ ពាក្យសម្តី...) របស់មនុស្សម្នាក់ៗ ដើម្បីស្គាល់ពីគុណសម្បត្តិ និងគុណវិបត្តិរបស់មនុស្សនោះ។

ឧទាហរណ៍: សង្កេតទៅលើចំណូលចិត្ត និងតម្រូវការរបស់អតិថិជន។ ការសង្កេលើសកម្មភាពការងាររបស់បុគ្គលិក(បុគ្គលិកគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន ឧស្សាហ៍ សកម្ម លះបង់)។

ខ/ **វិធីវិភាគផលិតផលសកម្មភាព:** នៅពេលដែលមនុស្សបង្កើតផលិតផល គឺពួកគេបានបន្សល់ទុកនូវស្លាកស្នាមបុគ្គលិកលក្ខណៈរបស់ពួកគេនៅក្នុងលទ្ធផលនោះ។ ដូចនេះឆ្លងកាត់ផលិតផលការងារ យើងអាចដឹងពីអត្តចរិត ឬ ឫកពាររបស់បុគ្គលនោះបាន។

**ឧទាហរណ៍:** តាមរយៈប្រាសាទអង្គរវត្តដែលបានបន្សល់ទុក នាំឲ្យយើងដឹងពីស្នាដៃរបស់បុព្វបុរសខ្មែរសម័យនោះ ថាជាមនុស្សឧស្សាហ៍ និងជាមនុស្សដែលមានបម្រុងប្រយ័ត្នខ្ពស់។

ក្រោយពីការត្រួតពិនិត្យមើលអក្សររបស់មនុស្សម្នាក់ យើងអាចដឹងពីអត្តចរិតរបស់មនុស្សនោះ ព្រោះបើយើងប្រុងប្រយ័ត្ននាំឲ្យការសរសេរបានស្អាត។

**គ/ វិធីសន្ទនា:**ជាលំនាំសួរ និងឆ្លើយដោយផ្ទាល់ រវាងអ្នកស្រាវជ្រាវ និងកម្មវត្ថុស្រាវជ្រាវ។ ហើយដោយសារសំណួរទាំងឡាយ ដែលបានគ្រោងទុកមុន យើងអាចស្គាល់បានពីចិត្តគំនិតអាថិកំបាំងរបស់មនុស្ស តាមការវិភាគលើប្រតិកម្មសម្ដីរបស់មនុស្ស ដែលយើងសន្ទនាជាមួយ។

**ឃ/វិធីតេស្ត:** តេស្តជាប្រភេទលំហាត់ ដែលគេដាក់ឲ្យកម្មវត្ថុធ្វើ។យើងរៀបចំកម្រងសំណួរដាក់ក្នុងក្រដាស់មួយ ហើយចែកឲ្យកម្មវត្ថុស្រាវជ្រាវ និងអនុញ្ញត្តិឲ្យគេបំពេញរាល់សំណួរទាំងនោះ បន្ទាប់មកទើបយើងប្រមូលចម្លើយហើយធ្វើការបូកសរុប។

**ង/វិធីពិសោធន៍:**វិធីនេះមានបំណងបង្កបាតុភូតចិត្តដែលត្រូវសិក្សាដើម្បីអាចសង្កេតពីបម្រែបម្រួលធាតុផ្សេងៗ របស់បាតុភូតនោះ។វិធីនេះអាចប្រព្រឹត្តទៅក្រោមរូបភាពពីរ: ពិសោធន៍ធម្មតា និង ពិសោធន៍ក្នុងមន្ទីរពិសោធន៍។

**ពិសោធន៍ធម្មតា:** ការពិសោធន៍នេះ គេរៀបចំឡើងក្នុងជីវភាព ឬ ក្នុងសកម្មភាពធម្មតារបស់មនុស្ស ដែលគេចង់ពិសោធន៍ ដូចជាក្នុងថ្នាក់រៀន ក្នុងល្បែង ក្នុងពលកម្ម។

ឧទាហរណ៍:យកប្រដាប់លេងជាច្រើនឲ្យកុមារទាំងឡាយលេងដូចជា: កាំភ្លើង ឡាន រទេះភ្លើង រថក្រោះ។ល។ ដើម្បីសង្កេតពីទំនោររបស់កុមារ។

**ពិសោធន៍ក្នុងមន្ទីរពិសោធន៍:** វិធីនេះប្រព្រឹត្តទៅនៅក្នុងមន្ទីពិសោធន៍ ក្នុងលក្ខខណ្ឌ ដែលធ្វើឲ្យលេចឡើងនូវបាតុភូតចិត្តដែលអ្នកពិសោធន៍ចង់បាន។ ការពិសោធន៍នេះអនុវត្តជាទូទៅចំពោះលំនាំចិត្តជាងចំពោះលក្ខណៈចិត្ត។ រហូតមកដល់សព្វថ្ងៃនេះត្រូវបានគេអនុវត្តយ៉ាងទូលំទូលាយ ហើយមន្ទីពិសោធន៍ទាំងនេះក៏មានសម្ភារៈបរិក្ខាកាន់តែប្រសើរឡើងដែរ។

វិធីនេះអាចផ្តល់លទ្ធភាពច្បាស់លាស់ ជាក់លាក់ ដោយសារការប្រើសម្ភារៈបរិក្ខាផ្សេងៗ។ គេប្រើវិធីនេះញឹកញាប់ នៅក្នុងមន្ទីពេទ្យ និងបន្ទប់សួរចម្លើយជនសង្ស័យ។

- **អត្ថប្រយោជន៍របស់ចិត្តវិទ្យា**

ចិត្តវិទ្យាមានសារៈប្រយោជន៍ពិសេសដល់ជីវភាពសង្គម:

- គ្រូពេទ្យត្រូវស្គល់ចិត្តរបស់អ្នកជម្ងឺ
- នាយទាហានត្រូវដឹងចិត្តពលទាហាន
- សិល្បករត្រូវស្គាល់ចំណូលចិត្តរបស់ទស្សនិកជន
- អ្នកលក់ត្រូវដឹងពីតម្រូវការរបស់អតិថិជន

នៅក្នុងគ្រួសារក៏ដូចគ្នាដែរ ស្វាមីត្រូវស្គាល់ចិត្ត ដឹងចិត្ត យល់ចិត្តរបស់ភរិយា ចំណែកភរិយា ត្រូវស្គាល់ចិត្ត យល់ចិត្ត ដឹងចិត្តស្វាមីរបស់ខ្លួន។ ម្តាយត្រូវស្គាល់ពីអាកប្បកិរិយា និងទំនោររបស់កូន...។ល។

ឯគ្រូបង្រៀនវិញ ក៏ត្រូវស្គាល់ចិត្តរបស់សិស្សដែរ ដើម្បីឲ្យការងារអប់រំរបស់ខ្លួនទទួលបានលទ្ធផល។ ច្បាប់ចិត្តវិទ្យាទាំងឡាយ ជាមូលដ្ឋាននៃការបង្កើតច្បាប់គរុកោសល្យ។